ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ　　　　**តាងនាមប្រជារាស្ត្រខ្មែរ**

លេខ : ៩៩　　　　**តុលាការកំពូល**

ចុះថ្ងៃទី ១៦-០៨-២០០៤

**សាលដីកា**　　　　បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០៦

លេខ : ០៥　　　　ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

ចុះថ្ងៃទី ១១-០១-២០០៦

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឃឹម | ប៉ុណ្ណ | ប្រធាន |
| ២-លោក | ឈឹម | ស៊ីផល | ចៅក្រម |
| ៣-លោក | វៀល | មួន | ចៅក្រម |
| ៤-លោក | យស់ | សួខឿន | ចៅក្រម |
| ៥-លោក | ម៉ុង | មុន្នីចរិយា | ចៅក្រមរបាយការណ៍ |

ក្រឡាបញ្ជី

លោក　យ៉ាង　ស្រ៊ុន

តំណាងមហាអយ្យការ

លោក　ស៊ិន　រិទ្ធ　ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ៤៧ " ង " ចុះថ្ងៃទី ២៤-០៥-២០០៤ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៩៩ ចុះថ្ងៃទី ១៦-០៨-២០០៤ របស់តុលាការកំពូល។

__ត្រូវចោទពីបទ__ : រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែព្រៃ ឃុំចំណោម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ១៩-១១-២០០០។

__ជនជាប់ចោទ__ : ឈ្មោះ ស៊ីន សារឿន "ចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ២២ឆ្នាំ ជាតិ ខ្មែរ កើតនៅភូមិស្រែព្រៃ ឃុំចំណោម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ការិតវប្បធម៌ថ្នាក់ទី ៣ សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វនស្លា ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ មុខរបររកស៊ីរត់ម៉ូតូឌុប ឪពុកឈ្មោះ ស៊ីន ជិម "រ" ម្តាយឈ្មោះ ព្រីង វន់"រ"។ ប្រពន្ធឈ្មោះ ឃួន គ្មានកូន។ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៦-២០០១ និងឃុំខ្លួននៅថ្ងៃទី ២២-៦-២០០១ ។ទោសពីមុនគ្មាន។

-មេធាវី កញ្ញា ស៊ាង បូរ៉ាវី

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សេង សួង " ចុងបណ្តឹងសាទុក្ខ " ភេទ ស្រី អាយុ ១៩ឆ្នាំ ជាតិ ខ្មែរ មុខរបររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិបោះទម្លាប់ ឃុំ ចំណោម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។

-មេធាវី លោក សេង សឿ

-កាលពីថ្ងៃទី ១៩-៦-២០០០ វេលាម៉ោង ៩យប់ ឈ្មោះ ស៊ីន សារឿន បានរំលោភសេពសន្ថវៈលើជនរងគ្រោះឈ្មោះ សេង សួង នៅចំណុចស្រែព្រៃ មានព្រំប្រទល់ភូមិបោះទម្ពាប់ ឃុំចំណោម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។ អំពើដែល ឈ្មោះ ស៊ីន សារឿន បានប្រព្រឹត្តនេះប្រកបដោយសកម្មភាពហឹង្សា ក្នុងរយៈពេលដែលជនរងគ្រោះកំពុងតែរួមដំណើរជាមួយ។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការខេត្តបន្ទាយមានជ័យសំរេច : រក្សាការចោទប្រកាន់លើឈ្មោះ ស៊ីន សារឿន ពីបទរំលោភសេពសន្ថវៈតាមបញ្ញត្តិមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១២៤ ចុះថ្ងៃទី ១៩-១១-២០០១ របស់តុលាការខេត្តបន្ទាយមានជ័យដែលមានសេចក្ដីសំរេចដូចតទៅ :

១-ផ្ដន្ទាទោសលើឈ្មោះ ស៊ីន សារឿន ភេទប្រុស ដាក់ពន្ធនាគារកំណត់ ០៧ ឆ្នាំ " ប្រាំពីរឆ្នាំ " គិតពីថ្ងៃចាប់ខ្លួន ១៩-៦-២០០០។ ពីបទរំលោភសេពសន្ថវៈប្រព្រឹត្តនៅភូមិស្រែព្រៃ ឃុំចំណោម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ កាលពី ថ្ងៃទី ១៩-១១-២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-បង្គាប់អោយឈ្មោះ ស៊ីន សារឿន បងប្រាក់សំណង់ថ្លៃជូសជុលការអន្តរាយ និងជំងឺចិត្តជាទឹកប្រាក់ចំនួន ២.០០០.០០០រៀល " ពីរលានរៀល " ឱ្យទៅជនរងគ្រោះឈ្មោះ សេង សួង នៅពេលសាលក្រមនេះមានអានុភាពតទៅ។ បើរង្វូសមិនព្រមសងប្រាក់ទេ ត្រូវដាក់គុកបង្ខំដល់រូបកាយដើម្បីទារប្រាក់ធនទណ្ឌតាមបញ្ញត្តិមាត្រា ៣,៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៣-វត្ថុតាង សំពត់ក្លិសសេចំនួន ០១ អាវដៃវែងចំនួន ០១ ខោទ្រនាប់ចំនួន ០១ដើមបង្ក្រាប ០២ដើម និងខ្សែរអាវចំនួន ០៣ ត្រូវរិបអូស និងបំផ្លាញចោល។

សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ហើយបើកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងឧទ្ធរណ៍តាមបណ្ដឹងលេខ ៣២ ចុះថ្ងៃទី ០៤-១២-២០០១ របស់ឈ្មោះ ស៊ីន សារឿន ដែលតវ៉ាមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ ១២៤ ចុះថ្ងៃទី ១៩-១១-២០០១ របស់តុលាការខេត្តបន្ទាយមានជ័យ លើសេចក្ដីសំរេចទាំងមូល។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ សំរេចតំកល់សាលក្រមរបស់តុលាការខេត្តដដែល ព្រោះជនជាប់ចោទពិតជាបានរំលោភលើជនរងគ្រោះប្រាកដមែន។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៨១"ង" ចុះថ្ងៃទី ០៤-១១-២០០៣ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤-១២-២០០១ របស់ជនជាប់ចោទឈ្មោះ ស៊ីន សារឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផុតរលឹងតតិច្បាប់។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ ១២៤ ចុះថ្ងៃទី ១៩-១១-២០០១ របស់តុលាការខេត្តបន្ទាយមានជ័យ ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះ សេង សួង កំបាំងមុខជនជាប់ចោទ និងចំពោះមុខមេធាវីការពារជនជាប់ចោទ ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់តាមបណ្តឹងលេខ ០២ ចុះថ្ងៃទី ០៦-១-២០០៤ របស់ឈ្មោះ ស៊ុន សារឿន តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៨១ " ង " ចុះថ្ងៃទី ០៤-១១-២០០៣ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌកំបាំងមុខជនជាប់ចោទលេខ ៤៧ "ង" ចុះថ្ងៃទី ២៤-៥-២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី ០៦-០១-២០០៤ របស់ឈ្មោះ ស៊ុន សារឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-បដិសេធសាលដីកាកំបាំងមុខលេខ ៨១ "ង" ចុះថ្ងៃទី ០៤-១១-២០០៣ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

៣-តំកល់សាលក្រមព្រហ្មទណ្ឌលេខ ១២៤ ចុះថ្ងៃទី ១៩-១១-២០០១ របស់តុលាការខេត្តបន្ទាយមានជ័យទុកជាបានការ ប៉ុន្តែវៀរលែងតែចំណុចទី ១ និងចំណុចទី ២ វាក្យខណ្ឌទី១ទៅជា :

ក-ផ្តន្ទាទោសឈ្មោះ ស៊ុន សារឿន ភេទប្រុស អាយុ ២២ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ "ប្រាំឆ្នាំ" គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ១៩-៦-២០០១ ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែព្រៃ ឃុំចំណោម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ១៩-១១-២០០១ ។ មាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-០៩-១៩៩២ ។

ខ-បង្គាប់ឱ្យឈ្មោះ ស៊ុន សារឿន សងសំណងរដ្ឋប្បវេណីចំនួន មួយលានរៀល ឱ្យទៅជនរងគ្រោះឈ្មោះ សេង សួង នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

ចំណុចផ្សេងពីនេះ នៃសាលក្រមរក្សាទុកជាបានការដដែល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះ លឹម វណ្ណា មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខ តាមបណ្តឹងលេខ ៧៦ ចុះថ្ងៃទី ១៦-៦-២០០៤ របស់លោក សេង សឿ ជាមេធាវី ការពារឱ្យជនរងគ្រោះតវ៉ាមិនសុខចិត្តពីសាលដីកាលេខ ៤៧ "ង" ចុះថ្ងៃទី ២៤-០៥-២០០៥ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី ២៣ខែ កញ្ញា ឆ្នាំ ២០០៤ របស់ឈ្មោះ សេង សួង ធ្វើឡើងតាមកំណត់ ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី ២៦ខែ កក្កដា ឆ្នាំ ២០០៥ របស់ឈ្មោះ ស៊ុន សារឿន ធ្វើឡើងតាមកំណត់ ច្បាប់ ។

-បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់តំណាងមហាអយ្យការអមតុលាការកំពូល ឡើងសន្និដ្ឋាននាពេលសវនាការថា : តាមការពិនិត្យលើសំណុំរឿងនេះឃើញថាឈ្មោះ ស៊ុន សារឿន ពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែនដោយមានភស្តុតាងគ្រប់គ្រាន់អាចចោទប្រកាន់បាន សូមតំកល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និងសារណារបស់ដើមបណ្តឹងឈ្មោះ សេង សួង ។

-បានស្តាប់សាវតាជាតិ និងសារណាតប របស់ជនជាប់ចោទឈ្មោះ ស៊ុន សារឿន ។

-បានស្តាប់មេធាវីលោក សេង សឿ ការពារឱ្យដើមបណ្តឹងបានឡើងសន្និដ្ឋាននាពេលសវនាការថា : កូនក្តីរបស់ខ្ញុំត្រូវបានជនល្មើសឈ្មោះ ស៊ុន សារឿន នេះចាប់រំលោភសេពសន្ថវៈ រហូតបានសំរេច និងមានការបង្ខិតបង្ខំគំរាមកំហែងផង ។ រឿងនេះត្រូវបានតុលាការខេត្ត សំរេចផ្តន្ទាទោសព្រមទាំងសំណង ៥លានរៀល មានលក្ខណៈសមស្របហើយ ប៉ុន្តែមកសាលាឧទ្ធរណ៍បែរជាបន្ថយសំណងទៅវិញ នៅត្រឹម ១លានរៀល ប៉ុណ្ណោះពុំសមល្មមនិងកិត្តិយសកូនក្តីរបស់ខ្ញុំឡើយ សូមក្រុមប្រឹក្សាមេត្តារក្សាសំណងតាមតុលាការខេត្តវិញ ។

-បានស្តាប់មេធាវីកញ្ញា ស៊ាង បូរ៉ាវី ការពារឱ្យជនជាប់ចោទបានលើកឡើងការសន្និដ្ឋានរបស់ខ្លួន នាពេលសវនាការថា កូនក្តីរបស់ខ្ញុំ ពិតជាបានប្រព្រឹត្តរំលោភសេពសន្ថវៈមែន តែនេះការត្រូវរ៉ូវគ្នាហើយក៏មិនសំរេចដល់ទីជាដែរ សូម្បីវិញ្ញាបនបត្រពេទ្យក៏បានបញ្ជាក់ហើយ ។ ឯការសំរេចរបស់សាលាឧទ្ធរណ៍សំរេចទាំងអង្គហេតុអង្គច្បាប់ល្មមសមស្របដែរ ដូច្នេះសូមអង្គសវនាការតុលាការកំពូលមេត្តាពិចារណា ។

-បានស្តាប់តំណាងមហាអយ្យការអមតុលាការកំពូល ពុំមានអ្វីសន្និដ្ឋានបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានរបស់ខ្លួនទុកនៅដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍.

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ.

-ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋាន របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

**<u>តុលាការកំពូល</u>**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៧៦ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៤ របស់ឈ្មោះ សេង សួង ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ចំលើយរបស់ជនរងគ្រោះ និងចំលើយរបស់ជនជាប់ចោទព្រមទាំងវត្ថុតាង ដែលត្រូវដកហូតបានពីទីកើតហេតុ គឺជាភស្តុតាងស៊ីសង្វាក់គ្នាដែលបញ្ជាក់ថា កាលពីថ្ងៃកើតហេតុ ១៩-១១-២០០០ ឈ្មោះ ស៊ុន សារឿន ពិតជាបានចាប់បង្ខំជនរងគ្រោះឈ្មោះ សេង សួង ដើម្បីរំលោភសេពសន្ថវៈពិតប្រាកដមែន ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចកែប្រែបទចោទប្រកាន់លើជនជាប់ចោទ ទៅជាបទប៉ុនប៉ងរំលោភសេពសន្ថវៈដោយសំអាងហេតុថា តាមវិញ្ញាបនបត្រលេខ ១១៧៣ ចុះថ្ងៃទី ២៣-១១-២០០០ របស់មន្ទីរពេទ្យបង្អែកស្រុកមង្គលបុរី បានសន្និដ្ឋានថា ការរំលោភសេពសន្ថវៈមិនមានភាពស៊ីជំរៅនោះជាការភន្តច្រឡំ ពីព្រោះថាថ្វីបើការរំលោភសេពសន្ថវៈដែលមិនមានភាពស៊ីជំរៅក៏ពិតមែន ប៉ុន្តែជនល្មើសបានសំរេចនូវគោលបំណងរបស់ខ្លួនហើយ ។

-យល់ឃើញថា ពិតជាមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ស៊ីន សារឿន ពីបទរំលោភសេពសន្ថវៈ ដោយសំរេចផល កាលពីថ្ងៃកើតហេតុ ១៩-១១-២០០០ នៅភូមិស្រែព្រៃ ឃុំចំណោម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ប៉ុន្តែដោយទណ្ឌកម្ម និងសំណងជំងឺចិត្តមានលក្ខណៈធូនល្មម និងព្យសនកម្មហើយនោះ គប្បីតុលាការកំពូលតំកល់ទុកជាបានការដដែល ដោយធ្វើការកែប្រែបទចោទឱ្យបានត្រឹមត្រូវឡើងវិញ តាមការកំណត់នៃមាត្រា ២២៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ទាំងជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណាការពារ និងសារណាតបដាក់ជូនមកតុលាការកំពូលរួចហើយ តែមិនបានចូលរួមក្នុងសវនាការនេះទេ ដូចនេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤៧ "ង" ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ តែផ្នែកគតិច្បាប់ត្រូវខ្លះខុសខ្លះ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីកំបាំងមុខជនជាប់ចោទ និង

## ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ ៧៦ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤ របស់ឈ្មោះ សេង សួង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយពីគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៧ "ង" ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែត្រង់ចំណុចបទចោទប្រកាន់ត្រូវកែប្រែពីបទ: ប៉ុនប៉ងរំលោភសេពសន្ថវៈ ទៅជាបទរំលោភសេពសន្ថវៈវិញ។

៣-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦។